# ច្បាប់ដែលតម្រូវឲ្យសិស្សម្នាក់ៗត្រូវទទួលបានជោគជ័យ (ESSA)៖
## ការទាក់ទងរបស់ច្បាប់នេះទៅនឹងក្មេងដែលគេជួយចិញ្ចឹម

**តើ ESSA គឺជាអ្វី?**

ច្បាប់ដែលតម្រូវឲ្យសិស្សម្នាក់ៗត្រូវទទួលបានជោគជ័យ (ESSA) គឺជាច្បាប់សហព័ន្ធដែលជំនួសឱ្យច្បាប់មិនបន្សល់កុមារ (NCLB) ហើយផ្តល់ឱ្យរដ្ឋនូវភាពអាចបត់បែនបានកាន់តែច្រើន។ បទបញ្ញត្តិសម្រាប់យុវវ័យដែលនៅក្រោមការជួយចិញ្ចឹមរបស់គេ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា នឹងត្រូវអនុវត្តសម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ នេះ។

**តើ ESSA មានគោលបំណងអ្វីខ្លះ ជុំវិញក្មេងដែលនៅក្រោយការជួយចិញ្ចឹមរបស់គេ?**

ESSA ជួយបង្កើនការសហការគ្នារវាង អង្គការផ្ទែកមើលថែ កុមារ និង យុវវ័យ នៅទីក្រុងហ្វីឡាដែលហ្វ្យា ដែលក្រសួងផ្តល់ជំនួយផ្នែកមនុស្សជាតិ (DHS) និង ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា (SDP) ដើម្បីកែលម្អ ការបម្រើ និង លទ្ធផល របស់សិស្សដែលទទួលការជួយមើលថែ។ គេតម្រូវឲ្យ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ចាត់តាំងអ្នកធ្វើទំនាក់ទំនង ដើម្បីជួយសម្របសម្រួល និង អនុវត្តច្បាប់ថ្មីនេះ។

**តើតួនាទី របស់អ្នកសម្របសម្រួលនៃការជួយមើលថែក្មេង នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា គឺជាអ្វី?**

ធ្វើជាបណ្តាញអប់រំ រវាង ក្រសួងអប់រំ (SDP) និង ក្រសួងផ្តល់ជំនួយផ្នែកមនុស្សជាតិ (DHS) ដើម្បីកំណត់ ប្រយោជន៍ដ៏ចាំបាច់ ការសម្របសម្រួលនៃការដឹកជញ្ជូន និង ការចុះឈ្មោះ/កត់ត្រា ការផ្លាស់ប្តូរសាលា។

**តើបទប្បញ្ញត្តិពាក់ព័ន្ធអ្វីខ្លះ ដែលនៅក្រោមច្បាប់ ESSA ដែលប៉ះពាល់ដល់ក្មេងដែលស្ថិតនៅក្រោមការជួយចិញ្ចឹមរបស់គេ?**

ការសហការគ្នារវាង SDP និង DHS នឹងធានាថា៖

១) ក្មេងដែលស្ថិតនៅក្រោមការជួយចិញ្ចឹមរបស់គេ នឹងនៅរៀនក្នុងសាលារៀនដ៏ដែលរបស់ពួកគេ (សាលាដែលក្មេងបានចុះឈ្មោះ នៅពេលមានការចាត់តាំង) លុះត្រាតែមានការសម្រេចថា វាមិនមែនជាប្រយោជន៍ល្អបំផុតរបស់ពួកគេក្នុងការរៀននៅសាលានោះទេ។

២) ប្រសិនជាមានការសម្រេចថា វាមិនមែនជាប្រយោជន៍ល្អបំផុតរបស់ក្មេងក្នុងការរៀននៅសាលាដើមនោះគេ នឹងចុះឈ្មោះឲ្យក្មេងនោះចូលរៀននៅសាលាថ្មីភ្លាម ទោះបីជាពួកគេមិនអាចបង្ហាញឯកសារ តាមការតម្រូវនៃការចុះឈ្មោះចូលរៀននោះក៏ដោយ។

៣) សាលា (ចុះឈ្មោះចូលរៀន) ថ្មី ត្រូវទាក់ទងទៅសាលាដើមរបស់ក្មេង ដើម្បីរកឯកសារនៃការសិក្សា និងឯកសារពាក់ព័ន្ធដ៏ទៃទៀត។

៤) ការដឹកជញ្ជូនក្មេង ដែលស្ថិតនៅក្រោមការជួយចិញ្ចឹមរបស់គេ ត្រូវបានគេផ្តល់ឲ្យ ដែលអាចមានការជួយចេញថ្លៃខ្លះ៖

